- រដ្ឋកាលីហ្វ័រញ៉ាត្រូវគូសព្រំដែនមណ្ឌលសភា មណ្ឌលព្រឹទ្ធសភាតំណាងរដ្ឋ មណ្ឌលសភាតំណាងរដ្ឋ និងមណ្ឌលគណៈកម្មការសមភាពរបស់រដ្ឋសាជាថ្មីរៀងរាល់ដប់ឆ្នាំម្តង ដើម្បីឆ្លុះបញ្ចាំងពីទិន្នន័យជំរឿនប្រជាជនថ្មីរបស់សហព័ន្ធ។

- នៅមុនឆ្នាំ2008 សមាជិកសភារដ្ឋកាលីហ្វ័រញ៉ាបានគូសបន្ទាត់ព្រំដែនមណ្ឌលដោយខ្លួនឯង។ នៅក្នុងខែវិច្ឆិកា ឆ្នាំ2008 អ្នកបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ាបានអនុម័តច្បាប់បោះឆ្នោត Voters FIRST Act (“ច្បាប់”) ដែលអនុញ្ញាតឲ្យមានការបង្កើតគណៈកម្មការកំណត់បែងចែកមណ្ឌលបោះឆ្នោតសម្រាប់ពលរដ្ឋ (“គណៈកម្មការ”) ដើម្បីគូសបន្ទាត់ព្រំដែនមណ្ឌលថ្មី ដោយដកការងារនេះចេញពីដៃរបស់ពួកសភា។ នៅក្នុងឆ្នាំ2010 ច្បាប់បោះឆ្នោត Voters FIRST Act for Congress សម្រាប់សភា បានបន្ថែមទំនួលខុសត្រូវនៃការគូសផែនទីមណ្ឌលសភាទៅឲ្យគណៈកម្មការនេះ។

- ច្បាប់នេះតម្រូវឲ្យសវនកររបស់រដ្ឋកាលីហ្វ័រញ៉ា ដែលជាស្ថាប័នឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការគ្រប់គ្រងដំណើរការនៃការដាក់ពាក្យស្នើសុំសម្រាប់ការជ្រើសរើសសមាជិកគណៈកម្មការនេះ ដើម្បីឆ្លុះបញ្ចាំងពីភូមិសាស្ត្រ ជំនាញវិជ្ជាជីវៈ និងពិពិធភាពសង្គម។ គណៈកម្មការនេះមានសមាសភាព 14 រូបៈ ប្រាំរូបមកពីខាងប្រជាធិបតេយ្យ ប្រាំរូបមកពីខាងសាធារណៈរដ្ឋ និងបួនរូបទៀត ពុំមែនមកពីគណៈបក្សណាមួយឡើយ។

- ស្របគ្នាជាមួយវិធានតឹងរឹង គ្មានបក្សសម្ព័ន្ធដែលបង្កើតឡើងដើម្បីបង្កើតមណ្ឌលនានាដែលមានប្រជាជនស្មើគ្នា និងមានគោលបំណងក្នុងការផ្តល់ជូនតំណាងដែលត្រឹមត្រូវជូនដល់ពលរដ្ឋកាលីហ្វ័រញ៉ា គណៈកម្មការនេះ គូសព្រំដែនសម្រាប់មណ្ឌលសភា មណ្ឌលព្រឹទ្ធសភាតំណាងរដ្ឋ មណ្ឌលសភាតំណាងរដ្ឋ និងមណ្ឌលគណៈកម្មការសមភាពរបស់រដ្ឋ។ នៅពេលដែលគណៈកម្មការបានអនុម័តយកផែនទីចុងក្រោយចំនួនបួន ផែនទីនោះត្រូវបញ្ជាក់ជូនទៅខាងមន្ត្រីកិច្ចការរដ្ឋបាលរដ្ឋកាលីហ្វ័រញ៉ា ដោយមានរបាយការណ៍មួយពន្យល់អំពីមូលដ្ឋានដែលគណៈកម្មការនោះបានយកមកធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួន។

- គណៈកម្មការនេះ នឹងបើកកិច្ចប្រជុំជាសាធារណៈ និងទទួលយកមតិចូលរួមតាមមធ្យោបាយផ្សេងៗគ្នា ដើម្បីជួយខ្លួនក្នុងការគូសផែនទីមណ្ឌលថ្មីៗ។ សាធារណជនអាចចូលរួមបានដោយប្រគល់មតិយោបល់ជាសាធារណៈលើគេហទំព័ររបស់យើង នៅក្នុងកិច្ចប្រជុំណាមួយរបស់យើង តាមរយៈឧបករណ៍កំណត់ផែនទីសហគមន៍ផ្អែកតាមផលប្រយោជន៍រួម និងផ្ញើមតិចូលរួមរបស់ពួកគេតាមប្រៃសណីយ៍។

- គណៈកម្មការនេះ ត្រូវតែអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងនេះ តាមលំដាប់លំដោយនេះ នៅពេលគូសផែនទីមណ្ឌលៈ

  1. មណ្ឌលត្រូវតែមានប្រជាជនស្មើគ្នា ដើម្បីស្របទៅតាមរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក។
  2. មណ្ឌលត្រូវតែអនុវត្តតាមច្បាប់ស្តីពីសិទ្ធិបោះឆ្នោត ដើម្បីធានាថាជនជាតិភាគតិចមានឱកាសស្មើគ្នាដើម្បីជ្រើសរើសតំណាងតាមជម្រើសរបស់ពួកគេ។
  3. មណ្ឌលត្រូវគូសឲ្យជាប់ៗគ្នា ដើម្បីឲ្យគ្រប់ផ្នែកទាំងអស់របស់មណ្ឌលទាំងនោះ ត្រូវបានភ្ជាប់នៅជិតៗគ្នា។

4. មណ្ឌលត្រូវកាត់បន្ថយការបែងចែកជាទីក្រុង ខោនធី សង្កាត់ និងសហគមន៍ឲ្យបានជាអប្បបរមាតាមដែលអាចធ្វើបាន។
5. មណ្ឌលគប្បីបង្រួមតូចតាមតំបន់ភូមិសាស្ត្រ៖ តំបន់ប្រជាជនក្បែរខាងទាំងនោះ មិនត្រូវរំលងទៅដល់ប្រជាជននៅឆ្ងាយនោះទេ។ លក្ខខណ្ឌតម្រូវនេះ សំដៅយកដង់ស៊ីតេប្រជាជន មិនមែនរូបរាងទំហំប្រជាជនឡើយ។ ប្លុកធ្វើជំរឿន មិនអាចបំបែកបានឡើយ។
6. នៅត្រង់ចំណុចដែលអាចអនុវត្តបាន មណ្ឌលព្រឹទ្ធសភា ត្រូវរួមបញ្ចូលនូវមណ្ឌលសភាពេញលេញនិងក្បែរគ្នាចំនួនពីរ ហើយមណ្ឌលគណៈកម្មការសមភាពគប្បីមានមណ្ឌលព្រឹទ្ធសភាតំណាងរដ្ឋពេញលេញនិងក្បែរគ្នាចំនួន 10។